**គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា**
**CAMBODIAN HUMAN RIGHTS ACTION COMMITTEE**
ADHOC - CARAM - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP
IDA - KID - KIND - KKKHRA - KKKHRDA - KSA - KYA - LAC - PDP- PJJ - VIGILANCE
#9, St.330, Boeng Keng Kong III, Chamcar Morn, P.P Tel/Fax: (023) 218 759, Tel: 30 14 15, E-mail: chrac@forum.org.kh, chracsecretariat@yahoo.com

# សេចក្ដីថ្លែងការណ៍

## ការព្រួយបារម្ភជុំវិញការឃុំខ្លួនប្រជាពលរដ្ឋ ២ នាក់ ដែលទាក់ទងនឹងការដកបង្គោលតំរុយព្រំដែន កម្ពុជា-វៀតណាម នៅខេត្តស្វាយរៀង

គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា ដែលជាសម្ព័ន្ធអង្គការ-សមាគមមិនមែនរដ្ឋាភិបាលក្នុងស្រុក ចំនួន ២១ មិនពេញចិត្តចំពោះសាលាដំបូងខេត្តស្វាយរៀង ដែលបានសំរេចឃុំខ្លួនប្រជាពលរដ្ឋចំនួន ២ នាក់ ដែលទាក់ទងទៅនឹងការតវ៉ាអំពីការបាត់បង់ដីធ្លី ដោយសារការដាក់បង្គោលតំរុយព្រំដែន កម្ពុជា-វៀតណាម បានធ្វើឱ្យប៉ះពាល់ដីស្រែរបស់ពួកគាត់។

ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ តុលាការខេត្តស្វាយរៀង បានចេញដីកាកោះហៅប្រជាពលរដ្ឋចំនួន ៥ នាក់ នៅភូមិកោះក្បានខាងជើង ឃុំសំរោង ស្រុកចន្ទ្រា ខេត្តស្វាយរៀង ឱ្យចូលមកបំភ្លឺតុលាការ នៅព្រឹក ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៩ ដោយចោទប្រកាន់ពីបទ *"ធ្វើឱ្យខូចខាតដោយចេតនាបង្គោលតំរុយព្រំដែន កម្ពុជា-វៀតណាម លេខ ១៨៥"*។ ប្រជាពលរដ្ឋ ៣ នាក់ក្នុងចំណោម ៥ នាក់ បានមកតុលាការ ដោយចៅក្រមស៊ើបសួរហៅសួរម្នាក់ម្ដងៗ ហើយបានឃុំខ្លួន ២ នាក់ ក្នុងចំណោម ៣ នាក់ ចំណែកប្រជាពលរដ្ឋម្នាក់ទៀតបានគេចខ្លួនចេញពីបរិវេណតុលាការ បន្ទាប់ពីឃើញប្រជាពលរដ្ឋ ២ នាក់នោះត្រូវបានតុលាការឃុំខ្លួន រីឯប្រជាពលរដ្ឋ ២ នាក់ ផ្សេងទៀត មិនបានចូលខ្លួនមកកាន់តុលាការការទេ។

គណៈកម្មាធិការប្រព្រឹត្តិកម្មកត់សំគាល់ថា ចំណាត់ការរបស់តុលាការខេត្តស្វាយរៀង ចំពោះប្រជាពលរដ្ឋទាំងនេះមិនបានធ្វើទៅតាមនីតិវិធីច្បាប់ទេ ពីព្រោះតុលាការមិនទាន់បានធ្វើការស៊ើបអង្កេតឱ្យបានច្បាស់លាស់ អំពីផលប៉ះពាល់ ឬ ការបាត់បង់ដីធ្លីបង្ករបង្កើនផលរបស់ប្រជាពលរដ្ឋ ដោយសារតែការបោះបង្គោលតំរុយព្រំ ដែនកម្ពុជា-វៀតណាមនោះ។ ទោះបីជាទង្វើរបស់ប្រជាពលរដ្ឋមានាការពាក់ព័ន្ធខ្លះៗ ទៅនឹងគណបក្សនយោបាយក្ដី តែការធ្វើឡើងរបស់ពួកគាត់ក៏ ដោយសារពួកគាត់កំពុងទទួលរងនូវការបាត់ដីសំរោប់ធ្វើកសិកម្មចិញ្ចឹមជីវិតដែរ។

គណៈកម្មាធិការប្រព្រឹត្តិកម្មយល់ឃើញថា ប្រជាពលរដ្ឋទាំងនេះបានទទួលរងនូវភាពអយុត្តិធមិ ព្រោះថា ពួកគាត់កំពុងបាត់បង់ដីធ្លីរួចទៅហើយៗ ត្រូវជាប់ឃុំឃាំងថែមទៀត ដែលទង្វើនេះត្រូវបានគេមើលឃើញថា ជាកាគំរាមកំហែង បំបាក់ស្មារតីដើម្បីកុំឱ្យប្រជាពលរដ្ឋហ៊ានធ្វើការតវ៉ារឿងក្ដីតទៅទៀតនៅថ្ងៃមុខ និងជាគំនៀបដើម្បីគាបសង្កត់លើអ្នកគាំទ្រយោបាយគណបក្សជំទាស់ ដែលជាផ្ទុយទាំងស្រុងទៅនឹងគោលការណ៍ប្រទេស ដែលកាន់លទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស។

*ឆ្លើយតបទៅនឹងបញ្ហានេះ គណៈកម្មាធិការប្រព្រឹត្តិកម្ម សូមផ្ដល់អនុសាសន៍ និងសំណូមពរ មួយចំនួន ដូចខាងក្រោម:*

-សូមឱ្យមានការសិក្សា និងស៊ើបអង្កេតឱ្យបានច្បាស់លាស់ ដោយឯករាជ្យ អំពីចំណុចដីទំនាស់ ដែលបានបោះបង្គោល

ព្រំដែននោះ ជាដីកម្មសិទ្ធិឯកជន ឬ ក៏ជាដីសាធារណៈរបស់រដ្ឋ ។

-សូមដោះលែងប្រជាពលរដ្ឋ ២ នាក់ ដែលកំពុងឃុំខ្លួនបណ្ដោះអាសន្នឱ្យមានសេរីភាពឡើងវិញ ព្រោះថា ទង្វើរបស់ពួកគាត់ គឺដើម្បីទាមទារយកដីធ្លីរបស់ពួកគាត់មកវិញ តែប៉ុណ្ណោះ ។

-សូមឱ្យអាជ្ញាធរគ្រប់ផ្នែក និង គ្រប់ជាន់ថ្នាក់ ជាពិសេសតុលាការបញ្ឈប់នូវការឃុំខ្លួនប្រជាពលរដ្ឋ ដែលទាក់ទងនឹងបញ្ហាដីធ្លីតទៅទៀត ។

-សូមតុលាការគ្រប់ជាន់ថ្នាក់ មេត្តាបញ្ឈប់ការចាប់ខ្លួនភ្លាមៗ នៅពេលដែលកោះហៅប្រជាពលរដ្ឋឱ្យចូលមកបំភ្លឺនៅតុលាការ ព្រោះប្រការនេះបានធ្វើឱ្យប្រជាពលរដ្ឋមានការខ្លាចរអាទៅលើប្រពន្ធ័តុលាការ និងកាន់តែបាត់បង់ជំនឿងទុកចិត្ត ព្រមទាំងលែងហ៊ានចូលមកបំភ្លឺនៅតុលាការទៀត នាថ្ងៃអនាគត ។

-សូមតុលាការគោរពនូវគោលការណ៍ក្រមព្រហ្មទណ្ឌ ដែលចែងថា ប្រជាពលរដ្ឋគ្រប់រូបត្រូវតែមានសេរីភាព និងសូមឱ្យអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ដែលអាចឱ្យតុលាការតំណើរការនីតិវិធីដោយមិនចាំបាច់ឃាត់ខ្លួន ជាពិសេសករណីដែលទាក់ទងទៅនឹងដីធ្លី ។

-សូមតុលាការ មេត្តាគោរពគោលការណ៍ក្រមនីតិវិធីរដ្ឋប្បវេណីថ្មី ដែលចែងថា អ្នកកាន់កាប់ដីធ្លីត្រូវសន្មតថា ជាម្ចាស់កម្មសិទ្ធិ រហូតមានការសំរេចពីតុលាការជាចុងក្រោយ ។

ភ្នំពេញ, ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៩


☏ ***សំរាប់ព័ត៌មានបន្ថែមសូមទាក់ទងៈ***

| | | |
|---|---|---|
| -លោក **ហង្ស ឆាយា** | ប្រធាន សំរបសំរួលគណៈកម្មាធិការប្រព្រឹត្តិកម្ម CHRAC | |
| | និង នាយកប្រតិបត្តិ KID | ទូរស័ព្ទលេខៈ ០១២ ៨៦៥ ៩១០ |
| -លោក **សុក សំអឿន** | នាយកប្រតិបត្តិ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា CDP | ទូរស័ព្ទលេខៈ ០១២ ៩០១ ១៩៩ |
| -លោក **នី ចរិយា** | ប្រធានផ្នែកស៊ើបអង្កេត សមាគមអាដហុក ADHOC | ទូរស័ព្ទលេខៈ ០១១ ២៧៤ ៩៥៩ |
| -លោកស្រី **សយ សាវឌ្ឍនី** | នាយិកាប្រតិបត្តិ អង្គការកម្ពុជា ដើម្បីជួយស្ត្រីមានវិបត្តិ CWCC | ទូរស័ព្ទលេខៈ ០៩២ ៩៩៣ ៣៩៨ |
| -លោកស្រី **ស៊ុន ចាន់សែន** | ប្រធានសមាគមយុវជនខ្មែរ KYA | ទូរស័ព្ទលេខៈ ០១៧ ៧៨៨ ៩៥៥ |